ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៦០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែប្រែតំបន់ការពារទេសភាពអាចទ្រពាំងថ្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ៦៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ស្តីពីការផ្ទេរព្រៃការពារ តំបន់អភិរក្សព្រៃឈើ តំបន់ព្រៃផ្តល់ផល និងសម្បទានដីសេដ្ឋកិច្ច រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន

- បានឃើញអនុក្រឹត្យលេខ១០០ អនក្រ.បក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតតំបន់ការពារទេសភាពអាងត្រពាំងថ្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.-**

ត្រូវបានកែប្រែតំបន់ការពារទេសភាពអាងត្រពាំងថ្ម ពីផ្ទៃដីទំហំ១២ ៦៥០(មួយម៉ឺនពីរពាន់ប្រាំមួយរយហាសិប)ហិកតា មកផ្ទៃដីទំហំ២៤ ២១២(ពីរម៉ឺនបួនពាន់ពីររយដប់ពីរ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យនិងខេត្តឧត្តរមានជ័យ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984) ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីតំបន់ការពារទេសភាពអាងត្រពាំងថ្មខាងលើនេះ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ១២ ៦៥០(មួយម៉ឺនពីរពាន់ប្រាំមួយហាសិប)ហិកតា ដែលមានចែងក្នុងអនុក្រឹត្យលេខ១០០ អនក្រ.បក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតតំបន់ការពារទេសភាពអាងត្រពាំងថ្ម និងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះឧត្តរ ដែលមានផ្ទៃដីទំហំ១១ ៥៦២(មួយម៉ឺនមួយពាន់ប្រាំរយហុកសិបពីរ)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ៖

- ធានាការថែរក្សានិងការពារសោភណភាពធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងសារព័នមជ្ឈដ្ឋានធម្មជាតិសម្រាប់គោលដៅកម្សាន្តនិងទេសចរណ៍
- ថែរក្សាការពារ វប្បធម៌ ប្រពៃណី ការអភិវឌ្ឍ និងសារៈសំខាន់ផ្នែកវប្បធម៌របស់សហគមន៍មូលដ្ឋាន
- រក្សាលំនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣.-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ការពារទេសភាពអាងត្រពាំងថ្ម ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តបន្ទាយមានជ័យ និងរដ្ឋបាលខេត្តឧត្តរមានជ័យ ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤.-**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី មានជាអាទិ៍ ដីលំនៅឋាន ដីស្រែចម្ការ ដីអាស្រ័យផលស្របច្បាប់របស់ប្រជាពលរដ្ឋ ដែលអនុលោមតាមអនុក្រឹត្យស្តីពីការបង្កើតតំបន់ការពារទេសភាពអាងត្រពាំងថ្ម អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និង អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984
1:150,000
0 2.5 5 10 km
Google Earth

**ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៣**

**ចំណុចនិយាមកានៃផែនទីតំបន់ការពារទេសភាពអាចក្រពាំងថ្ម**

| ID | X | Y |
|---|---|---|
| 1 | 310774 | 1548345 |
| 2 | 311851 | 1549347 |
| 3 | 314120 | 1547724 |
| 4 | 313544 | 1544272 |
| 5 | 317369 | 1544461 |
| 6 | 319119 | 1541559 |
| 7 | 320732 | 1539321 |
| 8 | 320514 | 1536818 |
| 9 | 320768 | 1533376 |
| 10 | 322281 | 1531133 |
| 11 | 319332 | 1528868 |
| 12 | 317996 | 1525243 |
| 13 | 316658 | 1524483 |
| 14 | 312901 | 1525601 |
| 15 | 311123 | 1526159 |
| 16 | 308698 | 1526904 |
| 17 | 306925 | 1527352 |
| 18 | 306951 | 1527935 |
| 19 | 306185 | 1528709 |
| 20 | 305796 | 1529675 |
| 21 | 305626 | 1530479 |
| 22 | 305487 | 1531454 |
| 23 | 304942 | 1532115 |
| 24 | 303999 | 1532504 |
| 25 | 303062 | 1532909 |
| 26 | 302222 | 1532947 |
| 27 | 301128 | 1532906 |
| 28 | 300623 | 1533610 |
| 29 | 299819 | 1533700 |
| 30 | 299481 | 1534457 |
| 31 | 299324 | 1535243 |
| 32 | 298851 | 1535790 |
| 33 | 297932 | 1536017 |
| 34 | 297034 | 1536402 |
| 35 | 296261 | 1536788 |
| 36 | 295312 | 1537052 |
| 37 | 294652 | 1537759 |
| 38 | 293954 | 1538533 |
| 39 | 293265 | 1539280 |
| 40 | 293320 | 1539727 |
| 41 | 292294 | 1540480 |
| 42 | 292178 | 1541415 |
| 43 | 291531 | 1542146 |
| 44 | 290545 | 1542542 |
| 45 | 289649 | 1543115 |
| 46 | 290097 | 1542801 |
| 47 | 291205 | 1542673 |
| 48 | 292034 | 1542165 |
| 49 | 292478 | 1541337 |
| 50 | 292516 | 1540409 |
| 51 | 293434 | 1540478 |
| 52 | 293612 | 1539091 |
| 53 | 294216 | 1538214 |
| 54 | 294974 | 1537508 |
| 55 | 295833 | 1536934 |
| 56 | 296775 | 1536618 |
| 57 | 297535 | 1536316 |
| 58 | 298454 | 1535866 |
| 59 | 299119 | 1535670 |
| 60 | 299689 | 1535070 |
| 61 | 299836 | 1534199 |
| 62 | 300217 | 1533842 |
| 63 | 300863 | 1533476 |
| 64 | 301409 | 1532984 |
| 65 | 302396 | 1533037 |
| 66 | 303237 | 1532829 |
| 67 | 304293 | 1532478 |
| 68 | 305007 | 1531970 |
| 69 | 305786 | 1531454 |
| 70 | 305734 | 1530418 |
| 71 | 305877 | 1529616 |
| 72 | 306353 | 1528664 |
| 73 | 307049 | 1528011 |
| 74 | 306998 | 1527435 |
| 75 | 310569 | 1526402 |
| 76 | 309716 | 1526805 |
| 77 | 308076 | 1527377 |
| 78 | 308939 | 1528457 |
| 79 | 309465 | 1529390 |
| 80 | 310092 | 1528888 |
| 81 | 311067 | 1528611 |
| 82 | 311320 | 1538778 |
| 83 | 310056 | 1538784 |
| 84 | 309640 | 1543040 |
| 85 | 307597 | 1542905 |
| 86 | 306178 | 1542235 |
| 87 | 305928 | 1541653 |
| 88 | 305329 | 1542856 |
| 89 | 304742 | 1544228 |
| 90 | 304983 | 1545232 |
| 91 | 304546 | 1545368 |
| 92 | 304365 | 1544863 |
| 93 | 303645 | 1544930 |
| 94 | 303624 | 1545798 |
| 95 | 302477 | 1548472 |
| 96 | 303891 | 1549387 |
| 97 | 307009 | 1549595 |
| 98 | 308007 | 1549345 |
| 99 | 309690 | 1548400 |